ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## តាមនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ

សាលាឧទ្ធរណ៍ភ្នំពេញ

លេខ ៩៧៥/០៨-១០-១២ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី១៥-០៧-២០១៣ ដែលមានសមាសភាពដូចតទៅៈ

**សាលដីកា**

លេខ ៨១ ក្រ.ឃ.ចុះ

ថ្ងៃទី ២២-៧-២០១៣

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៩៧៥ ចុះថ្ងៃទី ០៨-១០-២០១២ រវាង ៖

-ជនជាប់ចោទឈ្មោះ

១-[redacted] **ម៉ុនណាត** ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិឡាវ កើតនៅប្រទេសឡាវ មានទីលំនៅភូមិ [redacted] មុខរបរ មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០២ នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ខមុល**។

**ជាប់ចោទពីបទ** ៖ ការធ្វើបរដើងសារគ្រឿងញៀនហាមឃាត់ខុសច្បាប់

ប្រព្រឹត្តនៅចំណុចផ្សារគគី ផ្លូវជាតិលេខ១ ឃុំគគី ស្រុកកៀនស្វាយ ខេត្ត-កណ្តាល កាលពីថ្ងៃទី ១២-០២-២០១២ តាមមាត្រា ៣៣.១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-[redacted] **ហ៊ាំងស៊ើន** ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិវៀតណាម មុខរបរ មិន-

ពិតប្រាកដ កើតនៅក្រុងវថហិន ប្រទេសវៀតណាម ទីលំនៅសព្វថ្ងៃរាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួន)។

**ជាប់ចោទពីបទ** ៖ ជួញដូរគ្រឿងញៀនហាមឃាត់

ប្រព្រឹត្តនៅចំណុចផ្សារគគី ផ្លូវជាតិលេខ១ ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ១២-០២-២០១២ តាមមាត្រា ៣៣ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី ១២-០២-២០១២ វេលាម៉ោង ១៨.១៥ អនុវត្តតាមវិធីញុះញង់ឱ្យលក់គ្រឿងញៀនហាមឃាត់ខុសច្បាប់ កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀនបានចុះប្រតិបត្តិការណ៍បង្ក្រាបករណីជួញដូរគ្រឿងញៀនខុសច្បាប់ នៅចំណុចផ្សារគគី ឃុំគគី ស្រុកកៀនស្វាយ ខេត្តកណ្ដាល និងឃាត់ខ្លួនឈ្មោះ [redacted] ហ្វាំងស៊ើន និងឈ្មោះ [redacted] ប៊ុនណាត កំពុងប្រព្រឹត្តបទល្មើសជាក់ស្ដែង ព្រមទាំងដកហូតវត្ថុតាងគ្រឿងញៀន មេតំហ្វេតាមីន(ICE) ទម្ងន់ ៩១,៦ក្រាម ទូរស័ព្ទដៃពីរគ្រឿង និងរថយន្ត LEXUS ចំនួន០១គ្រឿង។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨១ក្រ-២ (យ) ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក/-ឈ្មោះ [redacted] ហ្វាំងស៊ើន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ០៧"ប្រាំពីរ" ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១៥ ០០០ ០០០រ,០០ រៀល "ដប់ប្រាំលានរៀល" ដាក់ចូលថវិការដ្ឋ។

ពីបទ: ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្សារគគី ឃុំគគី ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ១២-០២-២០១២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៣-២-ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់។

ខ/-ឈ្មោះ [redacted] ប៊ុនណាត ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥"ប្រាំ"ឆ្នាំ ដោយឱ្យអនុវត្តទោសគុក ដាក់ពន្ធនាគារកំណត់ ០២"ពីរ"ឆ្នាំ ទោសនៅសល់ឱ្យទទួលទោសព្យួរទាំងអស់ និងពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០រៀល "ដប់លានរៀល" ដាក់ចូលថវិការដ្ឋ។

ពីបទ: ការធ្វើជើងសារគ្រឿងញៀនច្បាប់ហាមឃាត់ ប្រព្រឹត្តនៅចំណុចផ្សារគគី ឃុំគគី ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី ១២-០២-២០១២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៣-១-ថ្មីនៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់ និងតាមមាត្រា ១០៦, មាត្រា ១០៧ ,មាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

២-បណ្ដេញចេញទណ្ឌិតឈ្មោះ [redacted] ហ្វាំងស៊ើន ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិវៀតណាម ពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់អនុវត្តទោសគុកពន្ធនាគារ - និងទោសពិន័យចប់ជាស្ថាពរតាមច្បាប់។ តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៣-វត្ថុចាប់យក តាមកំណត់ហេតុលេខ ១០៨ វត ចុះថ្ងៃទី ២០-០២-២០១២ របស់ថៅក្រមស៊ើបសួរ:



Scanned with CamScanner

-ស្រោមស័ពុក្រពណ៌គគីបិទជិត មានហត្ថលេខាសមត្ថកិច្ច និងស្នាមមេដៃពណ៌ក្រហម ព័ទ្ធជុំវិញ ដែលមានសរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនក្រាមពណ៌ ទម្ងន់ ៩១.៦ក្រាម ដែលជាសារធាតុស្មើ ៩១.៦ក្រាម គុណ ៨៦.១១ក្រាម ចែកនឹង ១០០ ស្មើនឹង ៧៨,៨៧៦៧ក្រាម ត្រូវរឹបអូសបំផ្លាញចោល។

-ទូរស័ព្ទដៃពីរគ្រឿងម៉ាក អាយហ្វូនចិន មួយគ្រឿង និងម៉ាកណូគា ១២០២ មួយគ្រឿងមានស៊ីម។

-រថយន្តម៉ាក Lexus ES 300 មួយគ្រឿង ពណ៌ខ្មៅ លេខ JTHBF 30G 220079985, លេខម៉ាស៊ីន 1MZ,4605267 ស្លាកលេខ PP2Q 5656 ខូចកុងតាក់បញ្ជាកៅអីឆ្វេងមានស្នាមរលាត់ជាច្រើន ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

តាមមាត្រា ៨៥ នៃច្បាប់ស្តីពីវិសោធនកម្មស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នាថ្ងៃទី ១៣-៧-២០១២ ចំពោះមុខជនជាប់ចោទទាំងពីរនាក់ និងប្រកាសជាសាធារណៈ នាថ្ងៃទី ០៨-៨-២០១២។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ**បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១០-០៨-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនណាត** និងឈ្មោះ [redacted] **ហ្យាំងស៊ើន** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨១ក្រ-២ (យ) ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-**បានឃើញ**របាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ១៥-០១-២០១៣។

-**បានឃើញ**សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការចុះថ្ងៃទី ២៦-០៥-២០១៣។

**<u>នាពេលសវនាការសាលាឧទ្ធរណ៍</u>**

ចៅក្រមអានរបាយការណ៍រឿង

-ឈ្មោះ [redacted] ប៊ុនណាត បានឆ្លើយថា ខ្លួនសុំដកបណ្តឹងឧទ្ធរណ៍វិញ។

-ឈ្មោះ [redacted] ហ្យាំងស៊ើន បានឆ្លើយថា ខ្លួនសុំពន្យាពេលសវនាការដើម្បីរង់ចាំមេធាវី។

**<u>តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា</u>**

១-បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] ហ្យាំងស៊ើន, [redacted] ប៊ុនណាត បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់តាមមាត្រា ៣៧៥ , ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត បានដកពាក្យបណ្តឹងឧទ្ធរណ៍វិញ ឃើញថាសាលាឧទ្ធរណ៍មិនគួរពិចារណាលើបណ្តឹងនេះទេ គួរតែពិចារណាទៅលើបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] យ៉ាំងស៊ើន។

២-រឿងនេះមានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] យ៉ាំងស៊ើន ដូចបទចោទប្រកាន់របស់អយ្យការ ដោយហេតុថាជាបទល្មើសជាក់ស្តែងសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទ ឆែកឆេររថយន្តរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត និង [redacted] យ៉ាំងស៊ើន ឃើញមានគ្រឿងញៀនមេតំហ្វេតាមីនចំនួន ៩១,៦ក្រាម ដែលមានសារធាតុសុទ្ធរហូតទៅដល់ ៧៨,៨៧៦៧-



Scanned with CamScanner

ក្រាម។

៣-សាលក្រមរបស់សាលាដំបូងសម្រេចត្រង់ចំណុចទី២ ផ្តន្ទាទោសលើឈ្មោះ [redacted] យ៉ាំង-ស៊ើន ត្រឹមត្រូវហើយ តំណាងមហាអយ្យការ សុំតម្កល់ទុកជាបានការ។

-មេធាវី [redacted] វិបុល ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានធ្វើពាក្យដកបណ្តឹងឧទ្ធរណ៍របស់គាត់វិញ ក៏ដូចក្នុងពេលសវនាការនា ហេតុនេះសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណា តាមការដកបណ្តឹងឧទ្ធរណ៍របស់កូនក្តីខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ការសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

## សាលាឧទ្ធរណ៍យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-៨-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត និងឈ្មោះ [redacted] យ៉ាំងស៊ើន ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត បានសុំដកពាក្យបណ្តឹងឧទ្ធរណ៍របស់ខ្លួន តាមពាក្យសុំចុះថ្ងៃទី ២៩-០១-២០១៣ រួចហើយ។ ហេតុដូចនេះគប្បីចំណាយបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣-៨-២០១២ លើជនជាប់ចោទឈ្មោះ [redacted] ប៊ុនណាត ចេញពីបញ្ជីក្តី។

ហេតុដូច្នេះ

## ១និច្ឆ័យសេចក្តី

១-ចំណាយបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣-៨-២០១២ របស់ឈ្មោះ [redacted] ប៊ុនណាត ចេញពីបញ្ជីសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧៥ ចុះថ្ងៃទី ០៨-១០-២០១២ របស់សាលាឧទ្ធរណ៍។

២-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ២២-៧-២០១៣។

សាលដីកានេះបានចូលស្ថាពរ និងមានអានុភាពអនុវត្តលើឈ្មោះ [redacted] **ប៊ុនណាត** ក្រៅពីនេះពុំមានអានុភាពអនុវត្តឡើយ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ ថ្ងៃទី ២. ខែ .. ឆ្នាំ ២០១៤

| បានឃើញ | |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned with CamScanner